ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៤៤៩១ ព.ណ.អ.ក.អ.ប

ថ្ងៃសុក្រ ១៣កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## ការអនុវត្តច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ និងប្រកាសស្ដីពីខសន្យាមិនសុចរិត ក្នុងវិស័យអចលនទ្រព្យនិងលំនៅដ្ឋាន

ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ រាជរដ្ឋាភិបាលកម្ពុជា បានកសាងសេចក្ដីព្រាងច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ និងត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឡាយព្រះហស្ដលេខាប្រកាសឱ្យប្រើ តាមរយៈព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ជាមួយគ្នានេះ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ «គ.ជ.ក.ប.» ក៏ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ដែលមានរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាប្រធាន និងមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ជាអនុប្រធាននិងជាសមាជិក។ គ.ជ.ក.ប. មានតួនាទីរៀបចំនិងផ្សព្វផ្សាយអំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ ព្រមទាំងដឹកនាំនិងត្រួតពិនិត្យលើការអនុវត្តច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទដែលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា កំពុងមានការរីកចម្រើនលើគ្រប់វិស័យគួរជាទីមោទនៈ ដែលក្នុងនោះ វិស័យអចលនទ្រព្យនិងលំនៅដ្ឋាន ក៏មានសន្ទុះកើនឡើងយ៉ាងខ្លាំងក្លាផងដែរ។ ជាមួយនឹងការរីកលូតលាស់ខ្លាំងបែបនេះ បានបង្កឱ្យមានការប្រកួតប្រជែងយ៉ាងផុលផុស ក្នុងវិស័យជួញដូរអចលនទ្រព្យ ដែលអាចនឹងបង្កលក្ខណៈ ឱ្យមានការប្រកួតប្រជែងមិនស្មោះត្រង់ ឬក៏បកេងយកផលចំណេញពីអ្នកប្រើប្រាស់ដោយហួសហេតុជាដើម។

កន្លងមកនេះ ក្នុងចរន្តនៃការទិញ លក់អចលនទ្រព្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងសង្កេតឃើញមានការប្រើប្រាស់ទម្រង់ស្តង់ដារនៃកិច្ចសន្យារបស់បុគ្គលធ្វើធុរកិច្ចមួយចំនួន មានភាពមិនសុចរិត។ ទម្រង់ស្តង់ដារនៃកិច្ចសន្យាខ្លះ មិនបានផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ស្នើសុំកែប្រែខចែងឬលក្ខខណ្ឌណាមួយនៃកិច្ចសន្យា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ពួកគាត់ឡើយ។ ទម្រង់ស្តង់ដារនៃកិច្ចសន្យាមួយចំនួន បានបង្កប់នូវខ្លឹមសារនិងខសន្យាមិនសុចរិត ដើម្បីកេងយកចំណេញហួសហេតុពីអ្នកប្រើប្រាស់។ ខសន្យាមិនសុចរិតទាំងនោះមានជាអាទិ៍៖ ខចែងអំពីការលើកលែង ឬកម្រិតការទទួលខុសត្រូវ



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

របស់បុគ្គលធ្វើធុរកិច្ចលើការធានាលើទំនិញនិង/ឬសេវារបស់ខ្លួន ខចែងដែលផ្តល់សិទ្ធិឱ្យបុគ្គលធ្វើធុរកិច្ចអាចកែប្រែឬផ្លាស់ប្តូរចំណុចសំខាន់ណាមួយលើប្រភេទ បរិមាណ តម្លៃ និងគុណភាពនៃទំនិញនិង/ឬសេវា ឬកែប្រែខសន្យាសំខាន់ៗនៃទម្រង់ស្តង់ដារនៃកិច្ចសន្យាផ្សេងទៀត ដោយមិនតម្រូវឱ្យមានការជូនដំណឹង និងការយល់ព្រមជាមុនពីអ្នកប្រើប្រាស់ និងខសន្យាដែលផ្តល់សិទ្ធិឱ្យបុគ្គលធ្វើធុរកិច្ចអាចបកស្រាយដោយឯកតោភាគី ឬរំលាយកិច្ចសន្យាតាមឆន្ទានុសិទ្ធិរបស់បុគ្គលធ្វើធុរកិច្ច។

ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ គ.ជ.ក.ប. បានរៀបចំប្រកាសលេខ០០៦៧ ព.ណ.អ.កបប.ប្រក ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ស្តីពីខសន្យាមិនសុចរិត សំដៅការពារផលប្រយោជន៍អ្នកប្រើប្រាស់ ទប់ស្កាត់ការបង្កើតទម្រង់ស្តង់ដារនៃកិច្ចសន្យាដែលមិនសុចរិត និងមានលក្ខណៈកេងចំណេញពីអ្នកប្រើប្រាស់។ កាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ ក្រសួងពាណិជ្ជកម្មបានសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំសិក្ខាសាលាដើម្បីផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ខ្លឹមសារនៃប្រកាសស្តីពីខសន្យាមិនសុចរិត និងប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីតំណាងក្រុមហ៊ុនអចលនទ្រព្យដែលកំពុងធ្វើធុរកិច្ចលើវិស័យនេះប្រមាណ១៥០ នាក់ និងមានតំណាងដែលអញ្ជើញមកពីនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចូលរួមធ្វើជាវាគ្មិនផងដែរ។

គ.ជ.ក.ប. សូមក្រើនរំលឹកដល់បុគ្គលធ្វើធុរកិច្ចលើវិស័យអចលនវត្ថុទាំងអស់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ពិសេសប្រកាស លេខ ០០៦៧ ព.ណ.អ.កបប.ប្រក ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ស្តីពីខសន្យាមិនសុចរិត ដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់ និងជំរុញឱ្យការប្រកួតប្រជែងប្រព្រឹត្តប្រកបដោយតម្លាភាព។

មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» ក្រសួងពាណិជ្ជកម្ម និងជាសេនាធិការរបស់ គ.ជ.ក.ប. ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ នឹងចាត់វិធានការយ៉ាងតឹងរឹងបំផុត ចំពោះបុគ្គលទាំងឡាយណាដែលត្រូវបានរកឃើញថាប្រព្រឹត្តបំពានទៅនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ឬបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត។

ទន្ទឹមនឹងនេះ គ.ជ.ក.ប. សូមអំពាវនាវដល់សាធារណជនទាំងអស់ ប្រសិនបើទទួលរងនូវភាពអយុត្តិធម៌ ពាក់ព័ន្ធនឹងការកេងយកចំណេញហួសហេតុ ពីបុគ្គលធ្វើធុរកិច្ចក្នុងវិស័យអចលនវត្ថុនិងលំនៅដ្ឋានតាមរយៈការរៀបចំនូវទម្រង់ស្តង់ដារនៃកិច្ចសន្យាដែលមិនសុចរិត អាចដាក់ពាក្យបណ្តឹងមកអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ដែលមានអាសយដ្ឋាន៖ ផ្លូវ១៨ ភូមិក្តីតាកុយ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឬទូរស័ព្ទលេខ៖ (១). ០២៣ ២៣១ ៨៥៦ និង (២). ០៩២ ៨៣០ ៨៥៦៕

សូមអរគុណ!